**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍**

# របាយការណ៍
# កិច្ចប្រជុំរួមប្រចាំខែសីហា ឆ្នាំ២០២១
# របស់ថ្នាក់ដឹកនាំអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍

នៅព្រឹកថ្ងៃអង្គារ ៨រោច ខែស្រាពណ៍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥ ត្រូវនឹងថ្ងៃទី៣១ ខែសីហា ឆ្នាំ២០២១ ចាប់ពីម៉ោង ៩:០០នាទីព្រឹក អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ បានរៀបចំកិច្ចប្រជុំថ្នាក់ដឹកនាំប្រចាំខែសីហា ឆ្នាំ២០២១ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ឯកឧត្តមទេសរដ្ឋមន្ត្រី **អៀង មូលី** ប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។ កិច្ចប្រជុំនេះមានការចូលរួមពី ឯកឧត្តម លោកជំទាវ លោក អ្នកស្រី និងនាងកញ្ញាជាអនុប្រធាន ទីប្រឹក្សា អគ្គលេខាធិការ នាយកខុទ្ទកាល័យ នាយករងខុទ្ទកាល័យ អគ្គលេខាធិការរង ប្រធាននាយកដ្ឋាន ជំនួយការ អនុប្រធាននាយកដ្ឋាន ប្រធានការិយាល័យ និងអនុប្រធានការិយាល័យ តាមបណ្ដាញវីដេអូ កម្មវិធី Zoom សរុបប្រមាណ៥៥នាក់/គណនី។

## គោលបំណងនៃកិច្ចប្រជុំដើម្បី ៖

- ធ្វើបច្ចុប្បន្នភាព សកម្មភាពការងាររបស់ថ្នាក់ដឹកនាំ និងអគ្គលេខាធិការដ្ឋាននៃអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។
- ត្រួតពិនិត្យ តាមដាន និងវាយតម្លៃពីស្ថានភាពរាលដាល និងការឆ្លើយតបនឹងមេរោគអេដស៍ ។
- ពិនិត្យ និងវាយតម្លៃពីសមិទ្ធផលដែលសម្រេចបាន និងឧបសគ្គក្នុងការអនុវត្តផែនការសកម្មភាព និងដាក់ផែនការបន្ត។

ជាកិច្ចចាប់ផ្ដើម ឯកឧត្តមទេសរដ្ឋមន្ត្រី និងជាប្រធានអង្គប្រជុំ មានប្រសាសន៍ស្វាគមន៍ដល់មន្ត្រីរាជការទាំងអស់ដែលបានចូលរួម និងបានជម្រាបជូនពីដំណើរការនៃកិច្ចប្រជុំ តាមរបៀបវារៈដូចខាងក្រោម ៖

១) បទបង្ហាញស្ដីពីរបាយការណ៍សង្ខេបស្ដីពីលទ្ធផលសកម្មភាពការងារប្រចាំខែសីហា និងទិសដៅការងារខែកញ្ញា ឆ្នាំ២០២១ ដោយឯកឧត្តម ឈឹម ឃិនដារ៉េត អគ្គលេខាធិការ។

២) បទបង្ហាញស្ដីពីការដឹកនាំដើម្បីបញ្ចប់ការរាលដាលជំងឺអេដស៍នៅកម្ពុជា ដោយឯកឧត្តម **ទា ផលា** អនុប្រធានទទួលបន្ទុកបច្ចេកទេស។

៣) មតិសំណេះសំណាលរបស់ឯកឧត្តមទេសរដ្ឋមន្ត្រី។

៤) កិច្ចការផ្សេងៗ។

បន្ទាប់មក ឯកឧត្តមទេសរដ្ឋមន្ត្រី បានអនុញ្ញាតជូន ឯកឧត្តម **ឈឹម មិនដារ៉េត** អគ្គលេខាធិការធ្វើរបាយការណ៍ស្តីពីលទ្ធផលសកម្មភាពការងាររបស់ថ្នាក់ដឹកនាំ និងអគ្គលេខាធិការដ្ឋាននៃអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ប្រចាំខែសីហា ឆ្នាំ២០២១ និងលើកទិសដៅសម្រាប់ខែកញ្ញា។

ដោយមានការអនុញ្ញាតពី ឯកឧត្តមទេសរដ្ឋមន្ត្រី ឯកឧត្តម **ឈឹម មិនដារ៉េត** អគ្គលេខាធិការ បានធ្វើបទបង្ហាញដោយផ្តោតលើចំណុចសំខាន់ៗស្តីពីលទ្ធផលសកម្មភាពការងារដូចខាងក្រោម ៖

**I- បទបង្ហាញរបាយការណ៍ស្តីពីលទ្ធផលសកម្មភាព ការងាររបស់ថ្នាក់ដឹកនាំ និងអគ្គលេខាធិការដ្ឋាន**

១- សកម្មភាពការងារដែលសម្រេចបាន ៖

- បានរៀបចំរបាយការណ៍សង្ខេបស្តីពីសកម្មភាពការងារ ដែលជាសមិទ្ធផលសំខាន់ៗសម្រេចបានរយៈពេល៥ឆ្នាំ (ឆ្នាំ២០១៧ ដល់ឆ្នាំ២០២១ ជូនរាជរដ្ឋាភិបាល។
- បានសម្ភាសជាមួយ Phnom Penh Post អំពីស្ថានភាព និងភាពជោគជ័យរបស់ប្រទេសកម្ពុជាក្នុងការឆ្លើយតបមេរោគអេដស៍ និងផ្សព្វផ្សាយដាក់ឱ្យប្រើប្រាស់ជាផ្លូវការក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ ឯកឧត្តមទេសរដ្ឋមន្ត្រី។
- បានសរសេរអត្ថបទកិច្ចប្រជុំស្តីពីការផ្សព្វផ្សាយការប៉ាន់ស្មានអំពីមេរោគអេដស៍ និងគោលដៅ ឆ្នាំ២០២៥ ជាភាសាខ្មែរ និងអង់គ្លេស ផ្សព្វផ្សាយ តាមទំព័របណ្តាញអ៊ីនធឺណេត និងទំព័រហ្វេសប៊ុក អ.ជ.ប.ជ.អ។
- បានចេញលិខិតណែនាំឱ្យរាជធានី ខេត្តចំនួន៤ ត្រៀមរៀបចំកៀរគរវិភាជថវិកាចំនួន ៨០.០០០.០០០រៀល សម្រាប់ផែនការអនុវត្តសកម្មភាព និងឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍។
- បានបញ្ចប់កិច្ចប្រជុំកម្រិតបច្ចេកទេសជាមួយក្រសួងផែនការ NCHADS UNAIDS និងដៃគូពាក់ព័ន្ធអំពីការរៀបចំយន្តការផ្តល់អត្តសញ្ញាណកម្មគ្រួសារក្រីក្រដល់អ្នកផ្ទុកមេរោគអេដស៍ នៅកន្លែងផ្តល់ឱសថប្រឆាំងមេរោគអេដស៍។
- បានផ្តល់ធាតុចូលសម្រាប់រៀបចំរបាយការណ៍ពាក់កណ្តាលអាណត្តិ ឆ្នាំ២០២១ នៃការអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍជាតិ២០១៩-២០២៣។
- បានរៀបចំសិក្ខាសាលាបណ្តុះបណ្តាលមន្ត្រីអគ្គលេខាធិការដ្ឋាន ផ្តល់ចំណេះដឹង និងជំនាញជាមូលដ្ឋានលើប្រធានបទក្នុងការអនុវត្តវិធីសាស្ត្រវិទ្យាសាស្ត្រសរសេររបាយការណ៍វឌ្ឍនភាព និងសមិទ្ធផលនៃការអនុវត្តផែនការ។ វគ្គគ្រប់គ្រង និងភាពជាអ្នកដឹកនាំ (ជំនាញទន់/បញ្ញាអារម្មណ៍) និងអនុសញ្ញានៃការលុបបំបាត់ការរើសអើងលើនារី។

២- បញ្ហាប្រឈម ៖

- ការអូសបន្លាយនៃការរាតត្បាតមេរោគកូវីដ-១៩ នៅតែបន្តផលប៉ះពាល់ដល់ការធ្វើអន្តរាគមន៍ និងការប្រមូលព័ត៌មាននៃការឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍។
- មិនអាចចុះអភិបាលនៅមូលដ្ឋាន។

៣- ជំហានសម្រាប់ខែបន្ទាប់ ៖

- ចុះអភិបាលតាមបណ្តាខេត្តនានា។

- បន្តរៀបចំផែនការសកម្មភាពថវិកា និងអនុវត្តសកម្មភាពសម្រាប់ការឆ្លើយតបនឹងមេរោគអេដស៍ ក្រសួង ស្ថាប័ន ពិសេស***គម្រោងទីក្រុងពន្លឿនការឆ្លើយតបនឹងជំងឺអេដស៍*** (FTC)។

## II- **បទបង្ហាញស្តីពីការដឹកនាំដើម្បីបញ្ចប់ការរាលដាលជំងឺអេដស៍នៅកម្ពុជា**

ឯកឧត្តមវេជ្ជបណ្ឌិត **ឆា ផលា** អនុប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ទទួលបន្ទុកបច្ចេកទេស បានបង្ហាញពីការដឹកនាំដើម្បីបញ្ចប់ការរាលដាលជំងឺអេដស៍នៅកម្ពុជា ហើយឆ្ពោះទៅសម្រេចគោលដៅ៩៥-៩៥-៩៥ នៅឆ្នាំ ២០២៥ យើងត្រូវ ៖

- ធ្វើឱ្យសម្រេចគោលដៅ PrEP។
- ត្រូវគិតគូរពី ART for PMTCT ដោយធ្វើឱ្យឡើងដល់ ៩៥%។
- ត្រូវធ្វើតេស្តរកមេរោគអេដស៍នៅក្នុងរដូវកូវីដ-១៩។
- ត្រូវកែធនធានឱ្យត្រូវនឹងស្ថានភាពបច្ចុប្បន្ន និងកែប្រព័ន្ធឱ្យមាននិរន្តរភាព។
- ភាពជាអ្នកដឹកនាំដែលត្រូវតែធ្វើការផ្លាស់ប្តូរ។
- ការអភិវឌ្ឍន៍វិស័យសុខាភិបាលតាមគំរូ 4s របស់ GFATM។
- ដៃគូទាំងអស់ ត្រូវវិវឌ្ឍពីកម្មវិធី (Program) ទៅការពង្រឹងប្រព័ន្ធ។
- មន្ត្រីទាំងអស់ត្រូវមានជំនាញទន់ (Soft Skills) ក្នុងការដឹកនាំ និងគ្រប់គ្រង។ ក្នុងនោះ អ្នកដឹកនាំត្រូវចាប់ផ្តើមមើលទៅលើសីលធម៌ និងក្រមសីលធម៌នៅក្នុងអ្នកដឹកនាំ។
- ត្រូវបញ្ចប់ការរីករាលដាលមេរោគអេដស៍ ដោយប្រើចរន្តជាតិតែមួយ និងពង្រឹងប្រព័ន្ធការអនុវត្តកម្មវិធី។
- ត្រូវប្រើប្រាស់ចំណុចគោលដៅសកល២០២៥ ក្នុងការពិនិត្យឡើងវិញនូវផែនការយុទ្ធសាស្ត្រ។
- ត្រូវមានយន្តការទប់ស្កាត់ករណីឆ្លងថ្មី ពិសេសក្រុមបុរសរួមភេទជាមួយបុរស និងបំប្លែងភេទ ដែលបច្ចុប្បន្នករណីថយចុះបានតែ៧៥% ហើយគោលដៅ៩០% បើធៀបនឹងឆ្នាំ២០១០។
- ត្រូវយកសេចក្តីជូនដំណឹងលេខ ២១៣ ស.ជ.ណ. មកអនុវត្ត។
- ត្រូវពង្រឹងប្រព័ន្ធថ្នាក់ក្រោមជាតិគាំទ្រកម្មវិធី។
- ត្រូវពង្រឹងស្ថាប័នឆ្លើយតបនឹងមេរោគអេដស៍។

## III)- **មតិសំណេះសំណាលរបស់ឯកឧត្តមទេសរដ្ឋមន្ត្រី**

១- អគ្គលេខាធិការ ត្រូវពិនិត្យមើល និងធ្វើបច្ចុប្បន្នភាពនូវអត្ថបទជាភាសាខ្មែរ និងភាសាអង់គ្លេស ឱ្យស៊ីសង្វាក់គ្នាពីការចុះផ្សាយនៅក្នុងគេហទំព័រ អ.ជ.ប.ជ.អ។ ចាត់តាំងឯកឧត្តម ស៊ិន ពិសិដ្ឋ ឱ្យរៀបចំអត្ថបទសង្ខេបជាភាសាអង់គ្លេសនៃកិច្ចប្រជុំនីមួយៗសម្រាប់ផ្សព្វផ្សាយតាមគេហទំព័រ (website) និងហ្វេសប៊ុក (Facebook) អាជ្ញាធរ។

២- អគ្គលេខាធិការដ្ឋាន ត្រូវរៀបចំមជ្ឈមណ្ឌលព័ត៌មាន ដោយធ្វើបច្ចុប្បន្នភាព បណ្ណាល័យ មានបដា ផ្ទាំងប៉ាណូ និងវីដេអូសម្រាប់ផ្សព្វផ្សាយអំពីវិធានការការពារ ការធ្វើតេស្តដោយខ្លួនឯង និងការចម្លងមេរោគអេដស៍ និងជំងឺអេដស៍នៅ អ.ជ.ប.ជ.អ។

៣- អ.ជ.ប.ជ.អ ទទួលបានជោគជ័យដោយអនុវត្តជាពហុវិស័យក្នុងការឆ្លើយតបទៅនឹងមេរោគអេដស៍ និងជំងឺអេដស៍ ដោយមានការចូលរួម និងគាំទ្រពីគ្រប់ស្ថាប័នជាតិ អន្តរជាតិ ដៃគូអភិវឌ្ឍន៍ សង្គមស៊ីវិល វិស័យឯកជន និងជាពិសេសបណ្តាញអ្នកផ្ទុកមេរោគអេដស៍។

៤- យើងមានស្ថាប័នដឹកនាំ គ្រប់គ្រង និងសម្របសម្រួលតែមួយ ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ហើយមានផែនការយុទ្ធសាស្ត្រជាតិ មានប្រព័ន្ធតាមដាន និងវាយតម្លៃជាតិតែមួយ។ វិធីដែលល្អ គឺសហការជាមួយក្រសួងមហាផ្ទៃ ដើម្បីឱ្យគណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍ រាជធានី/ខេត្ត ក្រុង ស្រុក/ខណ្ឌ និងឃុំ/សង្កាត់ ក្នុងការឆ្លើយតបទៅនឹងមេរោគអេដស៍ និងជំងឺអេដស៍ ប្រកបដោយប្រសិទ្ធភាពខ្ពស់។

៥- សម្រាប់ទៅថ្ងៃអនាគត បើគណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍ទាំងអស់បានដំណើរការបានល្អ **ឯកឧត្តមទេសរដ្ឋមន្ត្រី** នឹងអញ្ជើញ**សម្តេចក្រឡាហោម** ចុះទៅពិនិត្យនៅឃុំ/សង្កាត់ណាមួយដែលអនុវត្តបានល្អ។

៦- យើងត្រូវអនុវត្តឱ្យមានប្រសិទ្ធភាពតាមអនុសាសន៍ដ៏ខ្ពង់ខ្ពស់បំផុតរបស់ **សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី** ដែលបានអំពាវនាវដល់ជនរួមជាតិទាំងអស់ឱ្យចូលរួមជាមួយរាជរដ្ឋាភិបាលក្នុង **ចរន្តជាតិតែមួយ** ដើម្បីឆ្ពោះទៅសម្រេចគោលដៅនៅឆ្នាំ២០២៥។

៧- ចំពោះ *គម្រោងទីក្រុងពន្លឿនការឆ្លើយតបនឹងជំងឺអេដស៍* (FTC) គឺធ្វើទូទាំងខេត្ត ពិសេសនៅខេត្តបាត់ដំបង។ ចំណុចដែលត្រូវធ្វើឱ្យបាន គឺនៅ**ឃុំរការ** ដោយធ្វើជាគំរូ។

៨- ពិភពលោកកំពុងផ្តោតចក្ខុតម្រង់មកកម្ពុជា ដើម្បីរៀនសូត្រពីកម្ពុជា ហើយយកប្រទេសកម្ពុជាធ្វើជាគំរូ។

៩- សមិទ្ធផលដែលយើងទទួលបានមានជាបន្តបន្ទាប់ ដូចជា នៅតាមខេត្ត ក្រុង កំពុងរៀបចំគណៈកម្មាធិការប្រយុទ្ធនឹងអេដស៍ បានបង្កើនថវិកាជាតិជាប្រចាំ និងរាជរដ្ឋាភិបាលបានសម្រេចចេញ*សេចក្តីជូនដំណឹងលេខ២១៣សជណ.សស*។

១០- មន្ត្រីរាជការអាចចុះបេសកកម្មបានដោយប្រើថវិកាមូលនិធិសកល (GF) ដោយគោរពនូវវិធានការសុខាភិបាល ៣ការពារ ៣កុំ។

១១- មុខសញ្ញាសំខាន់បំផុត គឺ*ក្រុមបុរសរួមភេទជាមួយបុរស* (MSM) *អ្នកបំប្លែងភេទ* (TG) និងអ្នកចាក់គ្រឿងញៀនដែលមានហានិភ័យខ្ពស់នៃការឆ្លងជំងឺអេដស៍។ ត្រូវពិភាក្សាគ្នា ជាមួយដៃគូគ្រប់លំដាប់ថ្នាក់ ដើម្បីស្វែងរកវិធីដោះស្រាយ និងពីវិធានការការពារ ហើយផ្សព្វផ្សាយសារឱ្យបានទូលំទូលាយ ដើម្បីទៅដល់ក្រុមគោលដៅទាំងនោះ (MSM, TG & អ្នកចាក់គ្រឿងញៀន)។

១២- ប្រព័ន្ធធ្វើការងារប្រយុទ្ធប្រឆាំងនឹងជំងឺអេដស៍ទាំងអស់ ត្រូវដាក់បញ្ចូលក្នុងប្រព័ន្ធជាតិតែមួយ ទាំងក្នុងប្រព័ន្ធ និងក្រៅប្រព័ន្ធ ដែលមាន National data base Health & non health information input (ID poor..,)។

ជាទីបញ្ចប់ ឯកឧត្តមទេសរដ្ឋមន្ត្រី បានលើកទឹកចិត្ត និងណែនាំឱ្យមន្ត្រីទាំងអស់ បន្តកិច្ចខិតខំប្រឹងប្រែងទាំងអស់គ្នា ដោយយកចិត្តទុកដាក់ក្នុងការងារឱ្យបានកាន់តែប្រសើរឡើង ដោយមានការឯកភាពគ្នាជាធ្លុងមួយ មានសាមគ្គីភាពផ្ទៃក្នុងល្អ។

អង្គប្រជុំបានបញ្ចប់នៅវេលាម៉ោង១១:២៧នាទី ប្រកបដោយបរិយាកាសរីករាយ និងស្និទ្ធស្នាលក្រៃលែង។

ថ្ងៃអង្គារ ៩រោច ខែស្រាពណ៍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
រាជធានីភ្នំពេញ ថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០២១
អ្នកធ្វើរបាយការណ៍

ស៊ុត_ថេងផាន់

បានឃើញ និងឯកភាព
ទេសរដ្ឋមន្ត្រី ប្រធាន អ.ជ.ប.ជ.អ

អៀង_មូលី